# កំណត់របស់វិទ្យុសំឡេងកម្ពុជាក្រោមៈ

ដោយយល់ឃើញថា លោកឧត្តមសេនីយ៍ **ដៀន ដែល** ជាកុលបុត្រខ្មែរកម្ពុជាក្រោមម្នាក់ ដែលបានធ្វើពលិកម្មសព្វបែបយ៉ាងក្នុងជីវិតរបស់លោក ដើម្បីបម្រើនិងការពារទឹកដីកម្ពុជាក្រោម ក៏ដូចជាក្នុងការបម្រើនិងការពារប្រទេសកម្ពុជា ខ្ញុំបានធ្វើការបកប្រែអត្ថបទរបស់លោកបណ្ឌិត **ហ្គាហ្សា ពាងម៉េត** នេះមកពីភាសាអង់គ្លេដែលលោកសរសេរឡើងក្រោយមរណភាពរបស់លោកឧត្តមសេនីយ៍ ដែលខ្ញុំមានការគោរពជារៀមច្បងនិងជាអ្នកស្នេហាជាតិគម្រូម្នាក់។

មូលហេតុដែលខ្ញុំយកចិត្តទុកដាក់ក្នុងរឿងនេះ គឺម្យ៉ាងដោយខ្ញុំមានជំហ៊រជាក់ច្បាស់ទៅលើឧត្តមគតិមួយថាប្រជាពលរដ្ឋខ្មែរគួរតែបានដឹងអំពីប្រវត្តិរបស់វិរជនអ្នកស្នេហាជាតិពិតៗ ដែលបានប្តូរជីវិតការពារប្រទេសជាតិមាតុភូមិគ្រប់កាលសម័យដែលមានការឈ្លានពានពីបរទេស និងម្យ៉ាងទៀតដោយមើលឃើញថា ព្រឹត្តិការណ៍តស៊ូនៃ**រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ** ដែលកុលបុត្រកុលធិតាខ្មែរបានបូជាជីវិតដ៏ច្រើនមហិមា ហាក់ដូចជាស្ទើរតែរលប់បាត់ពីការយកចិត្តទុកដាក់របស់ខ្មែរជាទូទៅ សូម្បីមរណភាពរបស់លោកវិរជនឧត្តមសេនីយ៍ **ដៀន ដែល** ក៏មិនត្រូវបានគេរៀបចំជាធំដុំអ្វីដែរ ហើយប្រវត្តិជីវិតតស៊ូរបស់លោកក៏មិនត្រូវបានគេពិពណ៌នាក្បោះក្បាយដែរ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ព្រលឹងស្នេហាជាតិនៅតែសន្ធិតជុំក្នុងដួងចិត្តខ្មែរមួយចំនួនមានជាអាទិ៍អតីតយុទ្ធជនដែលនៅមានជីវិតរស់នៅគ្រប់ទីកន្លែង ដែលគួរតែផ្តល់នូវយុត្តិធម៌មួយដ៏សមរម្យចំពោះវិញ្ញាណក្ខន្ធលោកឧត្តមសេនីយ៍ខ្មែរដ៏អង់អាចក្លាហាន ជាការលើកតម្លៃដល់ខ្មែរអ្នកស្នេហាជាតិគ្រប់ៗជំនាន់។

ដោយឡែក ក្នុងនាមផ្ទាល់ជាអតីតយុទ្ធជននៃរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរម្នាក់ ខ្ញុំតែងសង្វេគនឹកគិតទៅដល់ជីវិតលំបាកលំបិនប្រកបដោយគ្រោះថ្នាក់ក្នុងព្រៃភ្នំក្រមថ្ម និងទឹកចិត្តតស៊ូប្តូរផ្តាច់របស់កុលបុត្រខ្មែរ គ្រាដែលប្រទេសជាតិត្រូវទ័ពបរទេសវាយលុកកាន់កាប់។ ផ្នែកមួយទៀតទាក់ទងលោកឧត្តមសេនីយ៍ **ដៀន ដែល** គឺដោយលោកឧត្តមសេនីយ៍ជាខ្មែរ **កម្ពុជាក្រោម** ដូចគ្នា យើងបានឆ្លងកាត់បទពិសោធន៍រស់នៅយ៉ាងអាមាស់ ឈឺចាប់ខ្លោចផ្សា ក្រោមការត្រួតត្រារបស់របបគ្រប់គ្រងយួនគ្រប់និន្នាការនយោបាយ។ ក្នុងស្ថានភាពនេះ ដែលយើងជា**ខ្មែរក្រោម** តែងបែងភាគខ្លួនជាពីរ ដៃម្ខាងខំធ្វើការដើម្បីជួយការពារបងប្អូនខ្មែរក្រោមដ៏អភព្វជិតដប់លាននាក់ ព្រមទាំងព្រះសង្ឃរាប់ម៉ឺនអង្គ ដែលត្រូវគេកាត់ផ្តាច់ចេញជាមួយដែនដី ហើយបោះចោលទៅឲ្យយួនដែលរាប់ថាជាសត្រូវប្រវត្តិសាស្ត្រ ហើយដែលជានិច្ចជាកាល ខ្មែរតែងទទួលពីរដ្ឋាភិបាលយួន នូវការជិះជាន់សង្កត់សង្កិនដោយគ្រប់រូបភាព មានការរំលោភសិទ្ធិមនុស្សជាមូលដ្ឋាន ការរំលោភសិទ្ធិសាសនាទំនៀមទម្លាប់ ប្រពៃណី សិទ្ធិនៃការរៀន ការនិយាយ និងការប្រើប្រាស់អក្សរនិងភាសាសាស្ត្រជាតិកំណើតរបស់

ខ្លួន សិទ្ធិការរួមប្រជុំ សិទ្ធិការផ្សាយនិងទទួលបាននូវព័ត៌មាន  សិទ្ធិនៃការធ្វើដំណើរ។ល។និង។ល។ ពោលឲ្យចំ គឺយួនមានបំណងក្នុងការបំបាត់ពូជសាសន៍ខ្មែរពីលើ**ទឹកដីកម្ពុជាក្រោម**តែម្តង។ ចំណែកដៃម្ខាងទៀត យើងតែង ព្យាយាមធ្វើអ្វីៗទាំងអស់ លះបង់អ្វីៗទាំងអស់ ដើម្បីចូលរួមការពារប្រទេសកម្ពុជាបច្ចុប្បន្ន កុំឲ្យធ្លាក់ទៅដូចទឹកដី **កម្ពុជាក្រោម** ទៀត។

ខ្ញុំសូមអរគុណជាពន្លឹក ចំពោះកំណត់ត្រារបស់លោកបណ្ឌិត **ហ្គាហ្វា ពាងម៉េត** អំពីសកម្មភាពអតីតកាល ដែលលោកបានចូលរួមជាមួយលោកឧត្តមសេនីយ៍ខ្មែរកម្ពុជាក្រោមម្នាក់ ហើយសង្ឃឹមថា អត្ថបទនេះយ៉ាងហោច ណាស់ ក៏បានបន្សល់ទុកជាឯកសារដ៏ត្រឹមត្រូវមួយ ដែលកូនខ្មែរជំនាន់ក្រោយត្រូវចងចាំនិងពិចារណា ចំពោះ ប្រវត្តិពិតនៃប្រទេសជាតិរបស់ខ្លួន ដើម្បីបុព្វហេតុការរស់រានមានជីវិតរបស់ខ្មែរនៅកម្ពុជាក្រោម ក៏ដូចជាចំពោះ ប្រទេសកម្ពុជាទៅអនាគត។

ថ្ងៃទី១ខែមិនា ឆ្នាំ២០១៣

ខ្ញុំព្រះករុណា-ខ្ញុំ **សឹង សម្រេច**

ខ្លឹមសារជាភាសាខ្មែរ នៃអត្ថបទដើមជាភាសាអង់គ្លេ ដោយ

បណ្ឌិត **ហ្គាហ្វា ពាងម៉េត**

## លោកឧត្តមសេនីយ ដៀន ដែល បានជូននូវអ្វីៗទាំងអស់ដែលលោកមាន ចំពោះខ្មែរ

អត្ថបទនេះ ជាការឧទ្ទិសចំពោះវិញ្ញាណក្ខន្ធលោកមេបញ្ជាការកងទ័ពដ៏មានល្បីឈ្មោះម្នាក់ លោក ឧត្តមសេនីយ **ដៀន ដែល** នៃសាធារណរដ្ឋខ្មែរពីឆ្នាំ១៩៧០-១៩៧៥ និងនៃ **កងទ័ពជាតិរំដោះ ប្រជាពលរដ្ឋខ្មែរ។** លោក **ដៀន ដែល** បានធ្វើការប្រយុទ្ធតតាំងជាមួយនឹងការកាន់កាប់ប្រទេសកម្ពុជា ដោយកងទ័ពវៀតណាម ពីឆ្នាំ ១៩៧៩-១៩៩០។

កើតនៅឆ្នាំ១៩៣២ នៅខេត្តឃ្លាំង(យួនបានប្តូរទៅជា សុក ត្រាំង) **កម្ពុជាក្រោម** សព្វថ្ងៃជាវៀតណាម ខាងត្បូង លោក **ដៀន ដែល** បានទទួលមរណភាពនៅទីក្រុងភ្នំពេញ កាលពីថ្ងៃទី១៣ខែកុម្ភៈ ឆ្នាំ ២០១៣។ សពរបស់លោកបានត្រូវបូជានៅថ្ងៃទី១៧ ខែកុម្ភៈ។

ខ្ញុំបានស្គាល់លោក **ដៀន ដែល** ជាមិត្តភក្តិ និងជាមិត្តរួមអាវុធ។ យើងបានជួបគ្នានៅប្រទេសកម្ពុជានៅពេលដែលខ្ញុំបានឈប់សម្រាកមួយឆមាស ពេលខ្ញុំនៅរៀននៅសាកលមហាវិទ្យាល័យនៅឡើយ ដើម្បីទៅសង្កេតការណ៍នៅសមរភូមិ ក្រោយថ្ងៃទី១៨មិនាឆ្នាំ១៩៧០ ដែលមានការទម្លាក់ព្រះប្រមុខរដ្ឋ **នរោត្តម សីហនុ។** នៅពេលនោះ លោក **ដៀន ដែល** ជាវរសេនីយឯក។

យើងមិនបានជួបគ្នាទៀត រហូតទាល់តែក្រោយខែឧសភាឆ្នាំ១៩៧៥ នៅសហរដ្ឋអាមេរិក។ នៅពេលនោះ លោក **ដៀន ដែល** ជាជនភៀសខ្លួន។ សាធារណរដ្ឋខ្មែរបានដួលរលំនៅថ្ងៃទី១៧ខែមេសា ក្រោយដែលសហរដ្ឋអាមេរិកបានដកថយពីតំបន់នោះ។ ភាគច្រើននៃសមាជិករដ្ឋាភិបាលបានប្រកែកមិនព្រមឡើងយន្តហោះដែលសហរដ្ឋអាមេរិកបានផ្តល់ឲ្យ ដើម្បីដឹកទៅទីមានសុវត្ថិភាព--រាប់ទាំងមេដឹកនាំ មានព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ ស៊ីរីម៉ាតាក់** ដែលត្រូវបានខ្មែរក្រហមសម្លាប់។

## តារាក្មេងវ័យ ដែលផុសអណ្តែតឡើង

តារាមួយដួងដែលផុសអណ្តែតឡើង លោក **ដៀន ដែល** កាលនោះជាឧត្តមសេនីយ៍ទោ មេបញ្ជាការកងពលធំលេខ២ នៅឆ្នាំ១៩៧២ ហើយជាមេបញ្ជាការកងទ័ពជើងគោក និងជាអភិបាលខេត្តកណ្តាលពីឆ្នាំ១៩៧៤ ដល់ថ្ងៃ ទី១៦ ខែមេសា ឆ្នាំ១៩៧៥។

ការយល់ស្រមៃរបស់លោកនិងអ្នកមួយចំនួនទៀត ក្នុងការរៀបចំមូលដ្ឋានក្រោយ នៅភូមិភាគឧត្តរទិសនៃកម្ពុជា នៅពេលដែលពួកខ្មែរក្រហមបានចូលកាន់កាប់ទីប្រជុំជននិងទីក្រុងនានានោះ ត្រូវទទួលបរាជ័យ ដោយសារស្ថានភាពដែនដីគ្មានស្ថេភាព ហើយឧទ្ធម្ភាគចក្រដែលដឹករូបលោក និងអ្នកមួយចំនួនទៀត ក៏បានចុះចតក្នុងទឹកដីថៃ។

នៅចុងឆ្នាំ១៩៧៥ លោក **ដៀន ដែល** ជាមួយភរិយានិងកូនពីរនាក់ ក្នុងឋានៈជាជនភៀសខ្លួន បានទៅដល់ទីក្រុង អាឡិចសង់ឌ្រីយ៉ា រដ្ឋ វៀរហ្សីនីញ៉ា។ ខ្ញុំបានក៏ជួបលោកសារជាថ្មី។

ពីរឆ្នាំក្រោយមក នៅខែឧសភាឆ្នាំ១៩៧៧ លោកបានចាកចេញពីសហរដ្ឋអាមេរិក ទៅប្រទេសបារាំង នៅទីនោះ លោកនិងរដ្ឋបុរសរៀមច្បង **សឺន សាន** បានរៀបចំជាគណកម្មការដើម្បីរំដោះកម្ពុជា។ នៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ១៩៧៩ លោកបានចាកចេញពីប្រទេសបារាំងទៅទីក្រុងបាងកក ហើយបន្ទាប់ពីនោះ ក៏ធ្វើដំណើរទៅតំបន់ព្រំដែន។

លោកបានបញ្ចុះបញ្ចូលក្រុមប្រដាប់អាវុធ១៣ក្រុម ឲ្យប្រមូលផ្តុំរួមជាមួយគ្នា។ នៅថ្ងៃទី៥ ខែមិនា ឆ្នាំ១៩៧៩ លោក **ដៀន ដែល** ប្រកាស**កងទ័ពជាតិរំដោះប្រជាពលរដ្ឋខ្មែរ** ; លោកបានត្រូវប្រសិទ្ធិនាមជាមេបញ្ជាការ។

នៅរដូវស្លឹកឈើជ្រុះឆ្នាំ១៩៨០ លោក **ដៀន ដែល** ស្លៀកសម្លៀកបំពាក់គ្រែអ៊ី បានបររទេះគោតាមផ្លូវបែកភក់ នាំខ្ញុំដែលទើបទៅដល់ថ្មីពីសហរដ្ឋអាមេរិក ដើម្បីបង្ហាញ"តំបន់រំដោះ" នៃ**រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ។**

នៅបន្ទាយអំពិល លោក **ដៀន ដែល** ជាមួយនិងសហការីស៊ីវិល លោក **ហ៊ីង គន្ធន់** បានបញ្ចូលខ្ញុំក្នុងថ្នាក់សកម្មជំនាន់ទីប្រាំ នៃការហ្វឹកហាត់សង្គ្រាមនយោបាយ។ លោក **ដៀន ដែល**បានចុះហត្ថលេខាលើសញ្ញាប័ត្ររបស់ខ្ញុំ នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៨០។ មួយឆ្នាំក្រោយមក នៅឆ្នាំ១៩៨១ លោក **ដៀន ដែល** បានបញ្ចូលខ្ញុំទៅសាលាយោធា ឲ្យចូលហ្វឹកហ្វឺនយោធាជាមួយនាយទាហ៊ានហ្វឹកហាត់ជំនាន់ទី១ នៃ **កងទ័ពជាតិរំដោះប្រជាពលរដ្ឋខ្មែរ។**

## សម្រុបខ្លួន ដើម្បីចូលរួម

លោក **ដៀន ដែល** និងលោក **ហ៊ីង គន្ធន់** បានសម្រេចបញ្ចូលខ្ញុំទៅក្នុងចលនាពន្លកថ្មី។ គេជម្រុញឲ្យគ្រប់គ្នាត្រូវសម្រុបខ្លួន(ខ្ញុំបានផ្លាក់ខ្លួនឈឺដាក់សេរ៉ូមព្យួរអស់មួយអាទិត្យ ដោយផឹកទឹកមិនស្អាត និងទទួលទានខ្យង ដែលរកបានមកពីថ្លុកត្រពាំងនៅជិតខាង) ដើម្បីនឹងត្រូវទទួលយកជាក្របខណ្ឌនៃ **រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ។** ដើម្បីនឹងត្រូវបានទទួលយក ខ្ញុំត្រូវបានណែនាំថា មានភ្នែកត្រូវសម្លឹងឲ្យឃើញច្រើន មានត្រចៀកត្រូវស្តាប់ឲ្យឮច្រើន មានមាត់ត្រូវទុកស្ងៀមសិន មុននិយាយ។ ខ្ញុំបានត្រូវណែនាំថា ខ្ញុំអាចនិយាយបាន តែនៅក្រោយរយៈពេលមួយដែលខ្ញុំបានសង្កេតពិនិត្យ និងពិចារណាបានច្រើនសិន បើមិនដូច្នោះទេ ខ្ញុំនឹងមិនបានទទួលទំនុកទុកចិត្តពីអ្នកដ៏ទៃទៀត ក្នុងទីលានសមរភូមិឡើយ។

ការបរិយាយរបស់អ្នកសង្កេតការណ៍បរទេស អំពីលោក **ដៀន ដែល** នៅក្នុងវីគីប៉េឌីយ៉ាត្រឹមត្រូវណាស់: លោក **ដៀន ដែល** បញ្ជាសេចក្តីគោរពពីថ្នាក់លើ ពីសហការី និងពីអ្នកក្រោមបង្គាប់; អ្នកសារព័ត៌មានមានការពិសោធន៍ បានឃើញលោក **ដៀន ដែល** ក្នុងការវាយប្រយុទ្ធ"មានការចាប់អារម្មណ៍"ចំពោះសភាពស្ងៀមស្ងាត់ និងក្នុងអារម្មណ៍គ្រប់គ្រងបានល្អរបស់លោក" លោកប្រហែលជាឧត្តមសេនីយ៍(កងទ័ព)ដ៏ល្អប្រសើជាងគេ បុរសដែលបញ្ចេញសញ្ញារីករាយចាំងក្នុងកែវភ្នែក... ដើរចព្រាប់ចុះឡើង

ក្នុងសម្លៀកបំពាក់ក្រឡាខ្លាឃ្លោករបស់លោក កាំភ្លើងខ្លីសៀតចង្កេះ និយាយថា **លោកនឹងធ្វើការប្រយុទ្ធលុះគ្រាអវសាន្ត។**″

ខ្ញុំបានធ្វើការងារជាមួយលោក **ដៀន ដែល** ក្នុងបរិយាកាសល្អនិងអាក្រក់។ លោកមានចំណុចខ្លាំងនិងចំណុចខ្សោយ។ ពេលដែលខ្ញុំនៅជាមួយលោកក្នុងសមរភូមិ ចរិតប្រកបដោយទំនុកទុកចិត្តរបស់លោក ជូនកាលផ្ទុយគ្នាជាមួយនឹងគ្រោះថ្នាក់ចំពោះមុខ។ ទោះជាយ៉ាងនោះក៏ដោយ លោកដូចជាមានការស្ទាក់ស្ទើរ ក្នុងការចុះហត្ថលេខាអនុញ្ញាតចំពោះបេសកកម្មទី១របស់ខ្ញុំ ក្នុងកងអនុសេនាធំ នៃ**កងទ័ពជាតិរំដោះប្រជាពលរដ្ឋខ្មែរ** ដើម្បីបំពេញបេសកកម្មឈ្លបនិងស្ទាបស្ទង់កម្លាំងខ្មាំងនៅទីតាំងបឹងអំពិលដែលត្រូវកាន់កាប់ដោយទ័ពវៀតណាម ដែលសម្បូរទៅដោយគ្រាប់មីន, ប៉ុន្តែលោកបានឲ្យខ្ញុំទៅដូចជាបោះថ្មមួយដុំចោល។ ជនជាតិអង់គ្លេម្នាក់ ក៏ទៅជាមួយនឹងម៉ាស៊ីនថតរបស់គាត់ដែរ។

នៅពេលយើងចេញដំណើរ  មេបញ្ជាការកងអនុសេនាធំរាយការណ៍តាមវិទ្យុ អំពីដំណើរវិវឌ្ឍន៍មកសេនាធិការ។ នៅពេលដែលមានការពើបប្រយុទ្ធ សម្លេងលោក **ដៀន ដែល** ឮរន្ថាន់ឡើង ពេលដែលខ្ញុំរវល់ថតរូបយុទ្ធជនដែលដេកដួលស្លាប់និងត្រូវរបួស ខ្លះមានឈាមជិតដាមជោគខោអាវ។ នៅពេលភ្លាមមួយនោះ ដៃមួយបានចាប់អូសទាញខ្ញុំ ហើយយើងក៏លោតទៅជ្រកក្រោយដំបូកមួយ។ ដោយមានគ្រាប់ផ្លោងធ្លាក់ផ្ទុះនៅចំកន្លែងដែលខ្ញុំទើបនឹងឈរប៉ុន្មានវិនាទីមុន ខ្ញុំលើកម៉ាស៊ីនថតឡើង តែទាហានម្នាក់បានចាប់ប្រានខ្ញុំចុះវិញ។ មេបញ្ជាការកងអនុសេនាធំបានរាយការណ៍តាមវិទ្យុមកថា ជនស៊ីវិលនៅក្នុងជួរ មិនអីទេ,ដោយខ្ញុំមានកង្វះបទពិសោធន៍ ខ្ញុំវិសត្រូវទទួលគ្រោះថ្នាក់មួយដល់ជីវិត។

## ល្អជាមួយពលទាហ៊ាន

នៅពេលដែលលោក **ដៀន ដែល** បានទទួលរបាយការណ៍ពីមិត្តអ្នកយកការណ៍សារព័ត៌មានបរទេសរបស់លោក --ប្រាប់ពីថ្ងៃដែលខ្មាំងនឹងបើកការវាយលុកមកលើទីបញ្ជាការ--លោកបានអនុញ្ញាតឲ្យខ្ញុំនៅចាំទីបញ្ជាការក្នុងលេនដ្ឋាន។ ខ្ញុំបានតាមមើលលោក **ដៀន ដែល** ជួបជាមួយមេបញ្ជាការរបស់លោក។ លោកបានយកខ្ញុំទៅជាមួយ នៅពេលដែលធ្វើដំណើរត្រួតពិនិត្យទ័ពខ្សែប្រយុទ្ធជួរមុខ។ លោកបាននិយាយកំប្លុកកំប្លែងជាមួយពលទាហ៊ាន ហើយផ្តល់គំនិតអំពីថាតើត្រូវលើកទំនប់ធំៗយ៉ាងណាដើម្បីទប់រថក្រោះ និងតើត្រូវពង្រាយមីននៅទីណាទៀត។

ដើរដល់ដើមឈើធំ ដែលគេតែងជឿថាជាលំនៅរបស់ព្រាយបិសាច លោក **ដៀន ដែល** ដកកាំភ្លើងខ្លីពីចង្កេះ ហើយបាញ់ដើមឈើនោះមួយគ្រាប់។

" ប៉ុណ្ណឹងទៅ បានហើយ" គាត់និយាយកំប្លែងលេង ។ អ្នកនៅជុំវិញលោកបញ្ចេញសំណើច ក្នុងក្តីចប់បារម្ភ។

ដូចជាបានដឹងមុនមែន ខ្មាំងផ្តើមបើកការវាយលុកនៅមុនពេលថ្ងៃរះ ហើយបន្តដោយការបាញ់ផ្លោងកាំភ្លើងធំអស់កន្លះព្រឹក។ ខ្ញុំនៅក្នុងលេនដ្ឋាន បន់ស្រន់កុំឲ្យដំបូលទីជម្រករលំបាក់ នៅពេលដែលគ្រាប់ផ្លោងធ្លាក់ចំពីលើ។ ព្រឹកឡើង លោក **ដៀន ដែល** បង្ហុយផ្សែងបារីនិងក្លិនស្រា ប្រាប់ខ្ញុំថាឲ្យរត់ទៅព្រំប្រទល់ដែនខ្មែរថៃ។

**"ត្រូវតែមានអ្នកនៅរស់ ដើម្បីបន្តការប្រយុទ្ធ។ យើងមិនត្រូវស្លាប់ទាំងអស់គ្នានៅទីនេះទេ"** គាត់ស្រែកខ្លាំងៗ នៅពេលដែលខ្ញុំតបវិញថា វាគ្មានពេលវេលាគ្រប់គ្រាន់ដើម្បីរត់ទៅដល់ព្រំប្រទល់ដែននោះទេ។ លោក **ដៀន ដែល** ក៏បានរុញខ្ញុំចេញពីលេនដ្ឋាន។

បន្ទាយអំពិលមិនត្រូវបានដួលរលំទេ នៅពេលនោះ។ អ្នកយកការណ៍ខ្លះបានពេបជ្រាយនឹងរបាយ-ការណ៍របស់យើងថា កងទ័ពនៃរណសិរ្សជាតិបានបាញ់កំទេចរថក្រោះច្រើនជាងចំនួនមួយគ្រឿង។ ទាល់តែប៉ុន្មានឆ្នាំក្រោយ  ក្រុមអ្នកតស៊ូវិលត្រឡប់ទៅវិញ ហើយថតរូបរថក្រោះដែលត្រូវច្រេះចាប់មួយគ្រឿង និងទិដ្ឋភាពទីលានប្រយុទ្ធ។ នៅពេលនោះ លោក **ដៀន ដែល** ជាអគ្គបញ្ជាការរង នៃ **កងទ័ពជាតិរំដោះប្រជាពលរដ្ឋខ្មែរ។** ប្រកបដោយបុគ្គលិកលក្ខណៈមានអំណាច និងធំធេងលើសពីជីវិត លោក **ដៀន ដែល** បានផ្តល់នូវអ្វីៗទាំងអស់ដែលលោកមាន ដើម្បីរបបគ្រប់គ្រងរបៀបសាធារណរដ្ឋមួយ ជូនប្រទេសកម្ពុជា ហើយលោកនឹងត្រូវជនរួមជាតិខ្មែរចងចាំមិនភ្លេច។

លោកបណ្ឌិត **ហ្គាហ្វា ពាងម៉េត** បានចូលនិវត្តពីសាកលវិទ្យាល័យ**ហ្គាម។** លោកជាអតីតឧបការី នៃមេបញ្ជាការ **កងទ័ពជាតិរំដោះប្រជាពលរដ្ឋខ្មែរ។** អាចទាក់ទងលោកតាមៈ
peangmeth@yahoo.com